ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣

ក្រសួងសុខាភិបាល

លេខ:.....041....កបស/មព

# ប្រកាស

## ស្តីពីការផ្តល់សិទ្ធិ

## ក្នុងការបើក បិទ និង ប្តូរទីតាំងរបស់សេវាវេជ្ជសាស្ត្រ

## អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ

៣៣៣

## ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីក្រសួងសុខាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០-១១-១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស រកម-០១៩៦-០៦ ចុះថ្ងៃទី២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យ វេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញព្រះរាជក្រឹត្យលេខ នស រកត ០២០០/០៣៩ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈគ្រូពេទ្យ

-យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## <u>សម្រេច</u>

<u>ប្រការ១:</u> ក្រសួងសុខាភិបាលផ្តល់សិទ្ធិជូនមន្ទីរសុខាភិបាលខេត្ត-ក្រុង ចេញលិខិតអនុញ្ញាតអោយបើកបន្ទប់ពិគ្រោះព្យាបាលជម្ងឺ បន្ទប់ពិគ្រោះព្យាបាលជម្ងឺមាត់-ធ្មេញ បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំជម្ងឺ បន្ទប់ព្យាបាលដោយចលនា ។

<u>ប្រការ២:</u> ការផ្តល់លិខិតអនុញ្ញាតនេះត្រូវអនុវត្តតាមប្រកាសលេខ០២០/០១ អបស-មព ចុះថ្ងៃទី០៧/០៩/០១ របស់ក្រសួងសុខាភិបាល ។

<u>ប្រការ៣:</u> ការបើក-ការបិទ ការប្តូរទីតាំង ឬប្តូរអ្នកទទួលខុសត្រូវ អាចប្រព្រឹត្តទៅបាន លុះត្រាតែបានទទួលការអនុញ្ញាតពីមន្ទីរសុខាភិបាលខេត្ត- ក្រុង ។

<u>ប្រការ៤:</u> ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ប្រការ៥:</u> ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានមន្ទីរពេទ្យ និងមន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ។

ភ្នំពេញ ថ្ងៃទី 22 ខែ 10 ឆ្នាំ២០០២

វេជ្ជ.ហុង-ស៊ុនហួត

<u>ចំលងជូន:</u>

-គ្រប់សាលាខេត្ត-ក្រុង

-ដូចប្រការ៥

-ឯកសារ-កាលប្បវត្តិ

ទីស្តីការក្រសួងសុខាភិបាល លេខ: ១៥១-១៥៣ វិថីកម្ពុជាក្រោម ភ្នំពេញ - ទូរស័ព្ទ/ទូរសារ (៨៥៥ ២៣) ៤២៦៨៤១ - ៧២២៩៣៣ - ៣១៣៤៥០
MINISTRY OF HEALTH: NO. 151-153 AVENUE KAMPUCHEA KROM, PHNOM PENH CAMBODIA, FAX/PHONE (855-23) 426841, 722933 E-mail: MOH@...